TIP TRAINING ON MAIZE PRODUCTION

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា
# ការដាំដុះដំណាំពោតក្រហម

២០០៩

ឌួច វ៉ាន់   ប៊ិប ម៉ាទីន

អង្គការ ឃែរ ប៉ៃលិន





គំរោង ផលិតកម្មដំណាំ និងទីផ្សារ (CCPMP)

គំរោង សហហរណកម្ម (ACIMA)

គំរោង សុវត្ថិភាពស្បៀងប្រចាំខេត្តប៉ៃលិន (PFSP)

EUROPEAN UNION

Australian Government

AusAID

CCPMP

care

## អារម្ភកថា

បទដ្ឋានអនុវត្តបច្ចេកវិទ្យា ផលិតកម្មដំណាំពោត បានចងក្រងឡើង គឺដើម្បីជាជំនួយដល់ភ្នាក់ងារផ្សព្វផ្សាយបច្ចេកទេសនៅតាមមូលដ្ឋាន និងកសិករដែលកំពុងអនុវត្តការងារផលិតកម្មដំណាំពោត ។ ឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យាដំណាំពោត គឺបានផ្តោតសំខាន់លើការបែងចែក វគ្គបណ្តុះបណ្តាល ទៅតាមដំណាក់កាលលូតលាស់នៃដំណាំ ប៉ុន្តែមិនបានលើកឡើងអំពីរបៀប ដែលភ្នាក់ងារផ្សព្វផ្សាយបច្ចេកទេសនៅតាមមូលដ្ឋានត្រូវរៀបចំផែនការសកម្មភាពសម្រាប់ការផ្សព្វផ្សាយរបស់ខ្លួនទេ ។ ឯកសារនេះត្រូវបានរៀបចំជាបីផ្នែករួមមានៈ

- វគ្គបណ្តុះបណ្តាលដំណាក់កាលទី១ ផ្តោតសំខាន់លើៈ ទីតាំងត្រូវដាំដុះពោត ការរៀបចំដី ពូជនិងការជ្រើសរើស,ការគ្រប់គ្រងស្មៅមុនពេលដាំ ការដាំដុះ និងការប្រើជីទ្រាប់បាត
- វគ្គបណ្តុះបណ្តាលដំណាក់កាលទី ២ ផ្តោតសំខាន់លើៈ ស្មៅ និងវិធានការកំចាត់ និង សារធាតុចិញ្ចឹម និងការប្រើជីបំប៉ន
- វគ្គបណ្តុះបណ្តាលដំណាក់កាលទី ៣ ផ្តោតសំខាន់លើៈ ការប្រមូលផល ការហាលសំងួត និង ការស្តុកទុក

ដោយមានការគាំទ្រថវិការពី សហគមន៍អឺរ៉ុប (EU) ក្នុងគំរោងសុវត្ថិភាពស្បៀងប្រចាំខេត្ត ប៉ៃលិន ជំនួយរដ្ឋាភិបាលប្រទេសអូស្ត្រាលី (AusAID) ក្នុងគំរោងសមាហរណកម្មសកម្មភាពមីន និង វិទ្យាស្ថានអន្តរជាតិអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) អង្គការឃែរ កម្ពុជា ប្រចាំខេត្តប៉ៃលិន បានរៀបចំចងក្រង និងបោះពុម្ពសម្រាប់ជា ជំនួយដល់ភ្នាក់ងារផ្សព្វផ្សាយ និងកសិករ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការងារ ផលិតកម្មដំណាំ ។

ខ្លឹមសារបច្ចេកទេស ត្រូវបានចងក្រងដោយផ្អែកលើលទ្ធផលនៃការពិសោធន៍ផ្ទាល់នៅនឹងចំការកសិករមានការគាំទ្រ បច្ចេកទេសពីអ្នកជំនាញនៃនាយកដ្ឋាន NSW Department of Primary Industry នៃប្រទេសអូស្ត្រាលី អ្នកជំនាញ បច្ចេកទេសកសិកម្មអង្គការឃែរកម្ពុជា បទពិសោធន៍ផ្ទាល់របស់កសិករ និងបានដកស្រង់ចេញពីឯកសារបច្ចេកទេសនានា ។

យើងខ្ញុំពិតជាជឿរជាក់ថា ឯកសាបច្ចេកទេសដែលមានលក្ខណៈសមញ្ញនេះ នឹងជួយសំរួលការងាររបស់អ្នកឱ្យចំណេញពេលវេលា និងបានជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវភ្នាក់ងារផ្សព្វផ្សាយនៅតាមសហគមន៍ក៏ដូចជាកសិករបានសិក្សា ស្វែងយល់បន្ថែមទាក់ទងទៅនឹង ការងារផលិតកម្ម ដំណាំពោតនៅតំបន់ខ្ពង់រាបប្រទេសកម្ពុជា ។ ទន្ទឹមនឹងនេះ កំហុសឆ្គង នៃការចងក្រងឯកសារនេះពិតជាមាន ដូច្នេះយើងខ្ញុំសូមអធ្យាស្រ័យរាល់កំហុសឆ្គងទាំងឡាយ និងរង់ចាំទទួលនូវការរិះគន់ ទាំងឡាយរបស់លោកអ្នកក្នុងន័យអភិវឌ្ឍន៍ ។

## សេចក្តីថ្លែងអំណរគុណ

បទដ្ឋានអនុវត្តបច្ចេកវិទ្យាផលិតកម្មដំណាំពោត បានរៀបរៀង និងបោះពុម្ពផ្សាយដោយសារ មានការជួយជ្រោមជ្រែងយ៉ាងពេញទំហឹងពីគំរោងចំនួន ៣ ដែលអនុវត្តដោយ អង្គការឃែរ កម្ពុជា គឺៈ

១. គំរោងសមាហរណកម្មសកម្មភាពមីន (ACIMA) ជំនួយរដ្ឋាភិបាលប្រទេសអូស្ត្រាលី (AusAID)

២. គំរោងសុវត្ថិភាពស្បៀងប្រចាំខេត្តប៉ៃលិន (PFSP) ដោយមានការគាំទ្រថវិការពី សហគមន៍អ៊ឺរ៉ុប (EU)

៣. គំរោងផលិតកម្មដំណាំ និងទីផ្សារ (CCPMP) វិទ្យាស្ថានអន្តរជាតិអូស្ត្រាលីសសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR)

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ

- លោក **ឌុក ពុន** ប្រធានកម្មវិធីអង្គការឃែរ ប្រចាំខេត្តប៉ៃលិនដែលបានចូលរួមក្នុងការផ្តួចផ្តើម និងផ្តល់ជាអនុសាសន៍ក៏ដូចជាគំនិតដ៏ល្អៗក្នុងការចងក្រងជាឯកសារនេះ ឱ្យកាន់តែមានភាពប្រសើរឡើង ។
- លោក **ហ្គ្រេក សេកុម្ប** (Greg Secomb) អតីតជាទីប្រឹក្សាបច្ចេកទេស អង្គការឃែរ ប្រចាំខេត្តប៉ៃលិនដែលបានផ្តួចផ្តើម និងផ្តល់ជាគំនិត ព្រមទាំងឯកសារដ៏ល្អៗ ក្នុងការរួមចំណែកធ្វើឱ្យឯកសារនេះកាន់តែមានភាពប្រសើរឡើង ។
- លោក **អាឡិច ហ្វ្រីមែន** (Alex Freeman)ជាអ្នកជំនាញកសិកម្ម ដែលបានផ្តួចផ្តើម និងផ្តល់ជាអនុសាសន៍ល្អៗក្នុងការចងក្រងជាឯកសារនេះឡើង ។
- លោកបណ្ឌិត **បប ហ្វាឃ្វាសុន** (Bob Farquharson) ជាគ្រូបណ្តុះបណ្តាលជាន់ខ្ពស់ នៃសាកលវិទ្យាល័យមែលបឺន (University of Melbourne) ដែលបានផ្តល់ជាអនុសាសន៍ដ៏ល្អៗនិងផ្តល់ឯកសារសំខាន់ៗ ដើម្បីធ្វើឱ្យឯកសារនេះ កាន់តែប្រសើរឡើង ។

យើងខ្ញុំក៏សូមថ្លែងអំណរអរគុណដ៏ស្មោះចំពោះបុគ្គលិកអង្គការឃែរទាំងអស់ដែលបានរួម ចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យឯកសារនេះបានលេចរូបរាង និងបោះពុម្ពផ្សាយ ។ ទន្ទឹមនឹងនេះ យើងខ្ញុំរង់ចាំផងដែររាល់ការរិះគន់នូវរាល់កំហុសឆ្គង ដើម្បីស្ថាបនាកែលំអពីសំណាក់ លោក លោកស្រី អ្នកនាង កញ្ញា ដែលជាអ្នកអានដោយក្តីកក់ក្តៅបំផុត ។ សូមអរគុណ !

**១. សេចក្តីអធិប្បាយ**........................................ ៥
សង្ខេបបច្ចេកទេស........................................ ៥
អនុសាសន៍បន្ថែម........................................ ៧
**២. គោលការណ៍បច្ចេកទេស**........................................ ៨
**វគ្គបណ្តុះបណ្តាលដំណាក់កាល ១**
១.១. ទីតាំងត្រូវដាំដុះ........................................ ៩
១.២. ការរៀបចំដី........................................ ១០
១.៣. ពូជ និងការជ្រើសរើសពូជ........................................ ១១
១.៤. ការគ្រប់គ្រងស្មៅមុនពេលដាំ........................................ ១៣
១.៥. បច្ចេកទេសដាំដុះ........................................ ១៥
១.៦. ដីទ្រាប់បាត........................................ ១៦
**វគ្គបណ្តុះបណ្តាលដំណាក់កាល ២**........................................ ១៧
២.១ ការគ្រប់គ្រងស្មៅ........................................ ១៨
២.១.១ ការប្រើថ្នាំពុលកសិកម្មកំចាត់ស្មៅ........................................ ១៨
២.១.១.១ ចំនុចសំខាន់គួរយល់ដឹង........................................ ១៨
២.១.១.២ ចំនុចសំខាន់ទាក់ទងទៅនឹងថ្នាំកំចាត់ស្មៅ........................................ ១៩
២.១.២. ថ្នាំកំចាត់ស្មៅផារាខ្វត........................................ ២១
២.១.៣. ថ្នាំកំចាត់ស្មៅ ២,៤-ឌី........................................ ២១
២.១.៤. សុវត្ថិភាពនៃការប្រើប្រាស់ថ្នាំកំចាត់ស្មៅ........................................ ២២
២.២. សារធាតុចិញ្ចឹម និងការប្រើជីបំប៉ន........................................ ២៥
២.២.១ សារធាតុ អាសូត........................................ ២៦
២.២.២ សារធាតុ ផូស្វរ........................................ ២៧
២.២.៣ សារធាតុ ប៉ូតាស្យូម........................................ ២៨
២.២.៤ របៀបដាក់ជីបំប៉ន........................................ ៣០
**វគ្គបណ្តុះបណ្តាលដំណាក់កាល ៣**........................................ ៣១
៣.១ ការប្រមូលផល........................................ ៣២
៣.២ ការហាលសំងួត និងស្តុកទុក........................................ ៣៣
**៣. ប្រភព**........................................ ៣៥

## សេចក្ដីសង្ខេបបច្ចេកទេស

| ខ្លឹមសារសំខាន់ៗ | ខ្លឹមសារគោល | ការអនុវត្តន៍មិនសមស្រប |
|---|---|---|
| ១. ទីតាំងត្រូវដាំដុះពោត | - ត្រូវដាំដុះពោតនៅកន្លែងសមស្រប (ដីមាន ជីជាតិ មិនដាំទឹក ជំរ៉ោដីជ្រៅ) | - ពោតដុះលូតលាស់មិនល្អ ចំពោះដីមានលក្ខណៈមិនសមស្រប |
| ២. ការរៀបចំដី | - ដី ត្រូវប្រាកដថា រៀបចំបាន ត្រឹមត្រូវ (ធ្វើឱ្យដីម៉ត់ ផុសល្អ និងរាបស្មើ) | - អត្រាដំណុះទាប និងដុះមិនស្មើគ្នា |
| ៣. ពូជ និងការជ្រើសរើស | - ប្រើពូជមានគុណភាពល្អ និងសមស្រប (ធានាពី ក្រុមហ៊ុនៈ ទិន្នផល រដូវកាលដំណុះ ធន់ទ្រាំនឹងជំងឺ ទីផ្សារ...) | - ទិន្នផលទាប ងាយទទួលរងការបំផ្លាញពីកត្តាចង្រៃនានា ... |
| ៤.ការគ្រប់គ្រងស្មៅមុនពេលដាំ | - ពេលវេលាភ្ជួរត្រូវសមស្រប ដែលអាចកាត់បន្ថយការលូតលាស់របស់ស្មៅ<br>- ការប្រើថ្នាំកំចាត់ស្មៅត្រឹមត្រូវ<br>- ថ្នាំកំចាត់ស្មៅ គ្លៃហ្វូសេត<br>- ថ្នាំកំចាត់ស្មៅ អាថ្រាស៊ីន | - នៅពេលភ្ជួរ ក្រោយភ្លៀង ៣-៤ ថ្ងៃ មិនអាចសំលាប់ស្មៅបានច្រើន តែកាន់តែធ្វើឱ្យស្មៅដុះកាន់តែច្រើន<br>- ប្រើថ្នាំ ដោយពុំស្គាល់ពីលក្ខណៈរបស់ថ្នាំ នឹងទទួលបានប្រសិទ្ធិភាពទាប និងចំណាយថវិការ |
| ៥. ការដាំដុះ | - ចន្លោះគុម្ព ចន្លោះជួរ និងជំរៅគ្រាប់<br>- លក្ខខណ្ឌនានាៈ សំណើមដី ធាតុអាកាស | -ដាំញឹកពេក ដំណាំមានការប្រគួតប្រជែងគ្នាយកជីជាតិ/សំណើម<br>-ដាំជ្រៅពេក ពន្លកមិនអាចដុះផុតពីដីបាន និងដាំរាក់ពេកដុះមិនល្អ |
| ៦. ការប្រើជីទ្រាប់បាត | - ការប្រើជីទ្រាប់បាត ដើម្បីបង្កើនជីជាតិដី ជំរុញការលូតលាស់ ជាពិសេសនៅពេលចាប់ផ្ដើមដំបូង<br>- ជ្រើសរើសប្រភេទជី សមស្របបំផុត | - ការប្រើជីមិនសមស្រប និងត្រូវពេលវេលា និងធ្វើឱ្យចំណាយថវិការឥតប្រយោជន៍ |

| | | |
|---|---|---|
| ៧. ស្មៅ និងវិធានការកំចាត់ | - យល់ដឹងអំពីលក្ខណៈទូទៅរបស់ថ្នាំ<br>- ថ្នាំកំចាត់ស្មៅ ផារាខ្វត<br>- ថ្នាំកំចាត់ស្មៅ ២,៤ ឌី<br>- ថ្នាំកំចាត់ស្មៅអាទ្រាស៊ីន<br>- សុវត្ថិភាពនៃការប្រើប្រាស់ថ្នាំពុល | - មិនអាចកំចាត់ស្មៅ តាមគោលបំណងក្នុងករណីប្រើថ្នាំខុស ឬពេលវេលា និងបច្ចេកទេសមិនសមស្រប<br>- អាចប៉ះពាល់ដល់សុខភាព ពេលប្រើថ្នាំពុលដោយមិនប្រើសំភារៈសុវត្ថិភាព |
| ៨. សារធាតុចិញ្ចឹម និងការប្រើ ជីបំប៉ន | - សារធាតុចិញ្ចឹមសំខាន់ ៣ សារធាតុអាសូត ផូស្វរ និង ប៉ូតាស្យូម<br>- ប្រភេទជីត្រូវប្រើពេលបំប៉ន<br>- របៀបដាក់ជីបំប៉ន | - សារធាតុចិញ្ចឹម បានដើរតួរយ៉ាងសំខាន់ក្នុងដំណើរការលូតលាស់របស់ដំណាំពោត ។ ដូច្នេះ នៅពេលខ្វះសារធាតុចិញ្ចឹម ការលូតលាស់ពោត ខ្សោយ និងបានទិន្នផលទាប ។ |
| ៩. ការប្រមូលផល | - លក្ខណៈសំគាល់ភាពទុំរបស់ពោតៈ (សំណើម អាយុកាល ពណ៌ដើម/គ្រាប់/ស្លឹក) | - ពោត នឹងបាត់បង់គុណភាពខណៈពេលប្រមូលផលពោតទុំមិនគ្រប់គ្រាន់ ឬទុំជ្រុលពេក |
| ១០. ការហាលសំងួត និងការស្តុកទុក | - គួរហាលសំងួតពោតភ្លាមក្រោយពេលប្រមូលផល ឬ ប្រលេះគ្រាប់រួច<br>-រយៈពេលស្តុកទុក ជាប់ពាក់ព័ន្ធទៅនឹង សំណើមរបស់គ្រាប់ (ស្តុកទុករយៈពេលវែង សំណើមគ្រាប់ត្រូវស្មើ/ទាបជាង១៣%) និងត្រូវមានថ្នាំការពារសត្វល្អិត<br>- ស្តុកទុកនៅកន្លែងសមស្រប និងមានសុវត្ថិភាព (ជង្រុក...) | - ពោតងាយនឹងធ្វើឱ្យអាប់ពណ៌ មានក្លិនស្អុយ ឡើងផ្សិត និងជំងឺផ្សេងៗក្នុងករណីសំណើមគ្រាប់ខ្ពស់<br>- ពោត នឹងដុះពន្លក ងាយរងការបំផ្លាញពីកត្តាចង្រៃនានា ខណៈពេលស្តុកមានសំណើមគ្រាប់ខ្ពស់ និងគ្មានថ្នាំការពារសត្វល្អិត |

- ពោតជាដំណាំដែលត្រូវការកំរិតជីជាតិខ្ពស់ជាពិសេសអាសូត ដូច្នេះមិនត្រូវដាំដុះពោតច្រើនឆ្នាំជាប់គ្នាទេ
- ពោតមានភាពធន់ខ្សោយចំពោះការជាំទឹក ដូច្នេះ មិនត្រូវដាំពោតនៅលើជាំទឹកទេ
- ដោយសារពូជពោតដែលកសិករកំពុងដាំជាពូជបង្កាត់ដូច្នេះចូរកុំព្យាយាមរក្សាទុកពូជសំរាប់ដាំដុះនៅរដូវបន្ទាប់
- ប្រភេទថ្នាំ កំចាត់ស្មៅ អាទ្រាស៊ីន (អាស្តាន) និង ២,៤-ឌី ជាថ្នាំកំចាត់ស្មៅ ប៉ុន្តែវាមិនមែនជាថ្នាំប៉ូវទេ
- ថ្នាំកំចាត់ស្មៅ អាទ្រាស៊ីន (អាស្តាន) ជាថ្នាំមិនអនុញ្ញាតិឱ្យប្រើប្រាស់នៅបណ្តាលប្រទេសនៃសហគមន៍អ៊ឺរ៉ុប ដោយសារកំរិតជាតិពុលនៅក្នុងដីយូរហើយត្រូវបានគេរកឃើញសារធាតុពុលនៅក្នុងទឹកក្រោមដី ទឹកស្ទឹង ទន្លេ
- ដាំនៅកំរិត ចន្លោះគុម្ព ០.៥ មចន្លោះជួរ ០.៧ ម ដាក់ ២ គ្រាប់ក្នុង ១ រណ្តៅ ឬ ចន្លោះគុម្ព ០.២៥ ម x ចន្លោះជួរ ០.៧ ម ដាក់ ១ គ្រាប់ក្នុង ១ រណ្តៅ
- ត្រូវគ្រប់គ្រងស្មៅឱ្យបានល្អ ក្នុងដំណាក់កាលលូតលាស់ជាការចាំបាច់ណាស់ដើម្បីធានាទិន្នផលខ្ពស់

## វគ្គបណ្តុះបណ្តាលដំណាក់កាល ១

### វគ្គបណ្តុះបណ្តាលដំណាំពោត ដំណាក់កាល ១ និងបង្ហាញអំពី:

### ១. ទីតាំងត្រូវដាំដុះពោត

### ២. ការរៀបចំដី

### ៣. ពូជ និងការជ្រើសរើសពូជ

### ៤. ការគ្រប់គ្រងស្មៅមុនពេលដាំ

### ៥. ការដាំដុះ

### ៦. ការប្រើជីទ្រាបបាត

វគ្គបណ្តុះបណ្តាលដំណាក់កាល ១ ធ្វើនៅដំណាក់កាលដាំដុះ ដោយជ្រើសរើសទីតាំងនៅចំការ ពោតដែលបានរៀបចំដីរួច ហើយអនុវត្តការងារបណ្តុះបណ្តាលដោយភ្ជាប់ទ្រឹស្តី ទៅនឹងការអនុវត្តន៍ជាក់ស្តែង ។ វគ្គបណ្តុះបណ្តាលនេះគឺផ្តោតសំខាន់លើ ៦ ចំណុច:

- ទីតាំងត្រូវដាំដុះពោត
- ការរៀបចំដី
- ពូជ និងការជ្រើសរើស
- ការគ្រប់គ្រងស្មៅមុនពេលដាំ
- ការដាំដុះ
- ការប្រើជីទ្រាប់បាត

## ១.១ ទីតាំងត្រូវដាំដុះពោត



រូបភាព ១ ដាំពោតនៅលើទីជំរាល ងាយទទួលរងសំណឹក ការហូរច្រោះ

- ពោតអាចដុះលូតលាស់ល្អនៅលើដីមានជំរៅជ្រៅយ៉ាងហោចណាស់ ០.៨ ម ឬ ជ្រៅជាងនេះ ។
- កុំដាំពោតដែលមានជំរេលខ្លាំង ព្រោះវាងាយនឹងហូរច្រោះនិងបាត់បង់ជីជាតិដីដែលរយៈពេលយូរនឹងមិនអាចធ្វើការដាំដុះដំណាំបានទេ ។

- ចូរកុំដាំពោតនៅលើដីជាំទឹកព្រោះពោតមានភាពធន់ខ្សោយ ចំពោះការជាំទឹក និងអាចខូចខាតទាំងស្រុង ខណៈពេលជាំទឹករយៈពេលយូរ ។



រូបភាព ២ ពោត មិនអាចដុះលូតលាស់បានល្អទេ លើដីជាំទឹក



រូបភាព ៣ ពោត ដុះលូតលាស់ល្អ នៅលើដីមានជីជាតិ និងច្រោះទឹកបានល្អ

## ១.២ ការរៀបចំដី

ការរៀបចំដីបានល្អ ចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការដាំដុះដំណាំពោតឱ្យទទួលបានជោគជ័យ ។

ហេតុអ្វីចាំបាច់ភ្ជួរដី ហើយការភ្ជួរដីមានគោលបំណងយ៉ាងដូចម្តេចមុនពេលដាំ?

- ធ្វើឱ្យដីម៉ត់ ផុសល្អ និងរាបស្មើល្អ
- ការបន្ថយការលូតលាស់របស់ស្មៅ

ប៉ុន្តែការភ្ជួរដី ក៏មានគុណវិបត្តិផងដែរ

- ការភ្ជួរដីធ្វើឱ្យបាត់បង់នូវសំណើមរបស់ដី ហើយនេះជាបញ្ហាសំខាន់ ជាពិសេសនៅរដូវដាំដុះដើមរដូវ
- ការភ្ជួរដីអាចធ្វើឱ្យស្មៅដុះកាន់តែច្រើន តាមរយៈ ការពង្រាយគ្រាប់ស្មៅ និងខ្នែងឫសស្មៅទៅកន្លែង



រូបភាព ៤ ការភ្ជួរដី មិនប្រាកដថា អាចសំលាប់ស្មៅបានទាំងស្រុងនោះទេ



រូបភាព ៥ ការភ្ជួរដី ធ្វើឱ្យបានបង់សំណើមរបស់ដី

តើយើងគួរភ្ជួរដីយ៉ាងដូចម្តេច ដើម្បីទទួលបានលទ្ធផលល្អ?

- គួរភ្ជួរដី ដែលមានសំណើមគ្រប់ ប៉ុន្តែបើសើមពេកវាធ្វើឱ្យពិបាកភ្ជួរ និងស្អិត
- ចំពោះដីជំរាល គួរភ្ជួរតាមគំនួសកាត់ទទឹង ដើម្បីកាត់បន្ថយការហូរច្រោះ និងសំណឹក
- ត្រូវភ្ជួរដោយមានល្បឿនថេរ និងកុំឱ្យលឿនពេក
- គួរធ្វើដីឱ្យម៉ត់ និងស្មើល្អ ជាពិសេសនៅពេលប្រើម៉ាស៊ីនសំរាប់ដាំ

ចំពោះការដាំពោតពីរដងក្នុងមួយឆ្នាំ គេតែងសង្កេតឃើញមានកសិករ ដុតកាកសំណល់ពោត មុននឹងធ្វើការភ្ជួរដីហើយ ការដុតនេះគឺមានគោលបំណងដើម្បីកាត់បន្ថយសត្វល្អិត ជំងឺ ស្មៅ និងមានភាពងាយស្រួលក្នុងការរៀបចំដី ។ តាមការសិក្សាស្រាវជ្រាវនាពេលថ្មីៗនេះបានបញ្ជាក់ថា ការរក្សាទុកកាកសំណល់ក្នុងចំការ គឺមិនធ្វើឱ្យជំងឺផ្ទុះឡើងជាយថាហេតុទេ ។ ប៉ុន្តែមុនពេលធ្វើការដុតកាកសំណល់ដំណាំពោត អ្នកគួរគិតអំពី ផលប៉ះពាល់ពាក់ព័ន្ធទៅនឹង ការបាត់បង់ធាតុអាសូត និងប៉ូតាស្យូមក្រោយពេលដុត ។ ធាតុអាសូតនៅក្នុងដី ងាយនឹងបាត់បង់ តាមរយៈសំណឹក ការហូរច្រោះ និងកំដៅ រីឯធាតុប៉ូតាស្យូមដែលមាននៅក្នុងកាកសំណល់ពោត ត្រូវបាត់បង់ខណៈពេលកាកសំណល់ ទាំងនេះត្រូវបានដុះ ។ កាកសំណល់ដំណាំពោតក៏ដើរតួរសំខាន់សំរាប់ជាគំរបដី ការពារសំណឹក ជីជាតិ សំណើមដី និងនៅពេលពុករលួយ ក៏ក្លាយទៅជាជីសំរាប់ដំណាំទៀតផង ។

### ១.៣- ពូជ និង ការជ្រើសរើសពូជ

រូបភាពខាងក្រោមនេះជាប្រភេទពូជបង្កាត់




រូបភាព ៦ ពូជបង្កាត់ មានច្រើនប្រភេទ និងនាំចូលពីកន្លែងផលិតផ្សេងៗកំពុងដាក់លក់ក្នុងទីផ្សារនៃប្រទេសកម្ពុជា

តើអ្វីជាពូជបង្កាត់?



នៅពេលពូជ មេ បា ពីរប្រភេទផ្សេងទៀត ត្រូវបានយក មក បង្កាត់ជាមួយគ្នា ពូជនៅជំនាន់បន្ទាប់ គឺជាពូជបង្កាត់ ។ លក្ខណៈរបស់ពូជបង្កាត់ គឺមិនអាចទុកពូជសំរាប់ធ្វើការដាំដុះ នៅជំនាន់ក្រោយបានទេ ។ លក្ខណៈរបស់ពូជបង្កាត់ គឺមិនដូចគ្នាទេ គឺអាស្រ័យទៅលើ មេ បា របស់ពូជ និងបច្ចេកទេស បង្កាត់ ។ ដូច្នេះ សូមកុំព្យាយាមយកពូជ បង្កាត់ សម្រាប់ដាំដុះនៅរដូវដាំបន្ទាប់ ។

រូបភាព ៧ ពូជបង្កាត់ មិនអាចរក្សាសំរាប់ដាំនៅរដូវក្រោយបានទេ

មានការលំបាក ចំពោះការផ្តល់អនុសាសន៍ក្នុងការជ្រើសរើសពូជ តាមរយៈការពិនិត្យមើលភ្នែកទទេណាស់ ព្រោះយើងមិនអាចដឹងអំពីលក្ខណៈពូជ ខណៈពេលដែលយើងមិនបានដាំឬឃើញអំពីការលូតលាស់ផ្ទាល់របស់ពូជ ។ អង្គការឃែរប្រចាំខេត្តប៉ៃលិន បានជ្រើសរើសពូជមានប្រភពមកពីក្រុមហ៊ុន ស៊ីភី( CP )និងផៃអូន្សេ (Poineer) គឺដោយសារតែធ្លាប់មានបទពិសោធន៍ទិញពូជពីក្រុមហ៊ុនជឿរជាក់ទៅលើកេរ្តិ៍ឈ្មោះ និងគុណភាពពូជ។តាមរយៈបទពីសោធន៍ផ្ទាល់របស់អង្គការឃែរប្រចាំខេត្តប៉ៃលិន ដែលធ្លាប់បានអនុវត្តការធ្វើពិសោធន៍ពូជនានា ការគាំទ្រពូជទៅដល់ សហគមន៍កសិករ គឺយើងបានជ្រើសពូជទៅតាមរដូវកាល ដែលមានលក្ខណៈ សមស្រប និងផ្តល់ទិន្នផលខ្ពស់:

- នៅដើមដៃ បានជ្រើសរើសពូជ ផៃអូន្សេ ៣០ កា ៩៥ (Poineer) ៣០ គ ៩៥




- ពូជ មានអាយុកាលលូតលាស់ខ្លី រយៈពេល ប្រហាក់ប្រហែល ១១០ ថ្ងៃ
- សមស្របទៅនឹងអាកាសធាតុប្រទេសកម្ពុជា (តំបន់ប៉ៃលិន)
- ដើមដងរឹងមាំ ធន់នឹងជំងឺ និងសត្វល្អិត
- ទិន្នផលខ្ពស់ (ផ្លែធំ តែមួយ/ដើម)
- ស្នូលធំ សមស្របសំរាប់លក់ទាំងគ្រាប់ និងនៅដើមដៃ

រូបភាព ៨ ផៃអូន្សេ ៣០ កា ៩៥សំរាប់ដាំដើមដៃ

- នៅចុងដៃ បានជ្រើសរើសពូជ ស៊ីភី ៨៨៨ ( CP 888 ) និងផៃអូន្សេ ៣០ បេ ៨០ (Poineer 30 B 80)

- ពូជទាំងពីរ មានលក្ខណៈប្រហាក់ប្រហែលគ្នា ទាក់ទងទៅ នឹង ទិន្នផល អាយុកាលលូតលាស់ និង ធន់ទ្រាំទៅនឹងជំងឺ និង សត្វល្អិតផ្សេងៗ
- សមស្របសំរាប់ការដាំដុះនៅចុងដៃ
- អាយុកាលជុំវិញ ១២០ ថ្ងៃ
- ស្នូលតូច
- ភាគច្រើនផ្លែ ២/ដើម




រូបភាព ៩  ផែអូឡេវ ៣០ បេ ៨០ និង ស៊ីភី ៨៨៨ សំរាប់ដាំនៅចុងដៃ

## ១.៤. ការគ្រប់គ្រងស្មៅមុនពេលដាំ

ស្មៅមិនត្រឹមតែបានប្រគួតប្រជែងយកជីជាតិពីដំណាំ  គឺបានប្រគួតប្រជែងយកពន្លឺ  ខ្យល់  និងទឹកពីដំណាំផងដែរ  ។ ខណៈពេលដែលភ្លៀងពុំគ្រប់គ្រាន់ ជាពិសេសនៅរដូវដាំដុះដើមដៃ  ការគ្រប់គ្រងស្មៅពុំបានល្អ  ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ទិន្នផលពោត តាមរយៈការប្រគួតប្រជែងយកសារធាតុចិញ្ចឹម ពន្លឺ  ខ្យល់ ជាពិសេសការប្រគួតប្រជែងយកទឹក ។ មានវិធីសាស្ត្រច្រើននៅក្នុងការគ្រប់គ្រង  និងកំចាត់ស្មៅដើម្បីទទួលបានជោគជ័យក្នុងការកំចាត់ស្មៅ។ អ្នកដាំដុះគួរតែរកវិធីសាស្ត្រធ្វើយ៉ាងណាឱ្យបរិមាណស្មៅមានចំនួនតិចហើយបន្តការគ្រប់ធ្វើឱ្យស្មៅកាន់តែតិចថែមទៀត។ ការអនុវត្តន៍បែបនេះជាចំនុចសំខាន់ក្នុងការធ្វើឱ្យការកំចាត់ស្មៅរបស់យើងទទួលបានជោគជ័យ ។

ចំពោះការគ្រប់គ្រងស្មៅនៅមុនពេលដាំ គឺយើងផ្តោតសំខាន់លើពេលវេលានៃការភ្ជួររាស់ និងការប្រើថ្នាំពុលគីមី៖




រូបភាព ១០ ៖ ក្លៃហ្វូសេត

- ការកាត់បន្ថយការភ្ជួររាស់តាមរយៈការភ្ជួរ៖  ជាទូទៅក្រោយ  ពេលភ្លៀងធ្លាក់ដីមានសំណើម  និងស្មៅចាប់ផ្តើមដុះរយៈ ពេល ៤-៥ ថ្ងៃក្រោយមានភ្លៀង ហើយនឹងបន្តដុះរហូត  ។ ដូច្នេះយើងគួរភ្ជួរដី នៅក្រោយពេលស្មៅបានដុះបានមួយរយៈមកទើបភ្ជួរលប់ជាការប្រសើរ  ។  ក្នុងករណីយើងភ្ជួរមុនពេលស្មៅដុះនោះ គោលបំណងនៃការភ្ជួរដី  ដើម្បីកាត់បន្ថយការលូតលាស់របស់ស្មៅ  នឹងមិនទទួលបានប្រសិទ្ធិភាពល្អទេ  ផ្ទុយទៅវិញ  វានឹងអាចធ្វើឱ្យស្មៅដុះកាន់តែច្រើន  ។ ដូច្នេះដើម្បីកាត់បន្ថយការលូតលាស់របស់ស្មៅ  យើងគួរភ្ជួរដីក្រោយពេលភ្លៀងរយៈពេលប្រហែល ១០ ថ្ងៃ ជាការប្រសើរ ។
- ការប្រើថ្នាំកំចាត់ស្មៅ៖ក្នុងករណីមានស្មៅដុះច្រើន  យើងគួរប្រើថ្នាំកំចាត់ស្មៅនៅមុនពេលភ្ជួរជាការប្រសើរព្រោះដើម្បីធានាថាស្មៅបានងាប់ល្អនៅមុនពេលភ្ជួរលប់។  នៅកម្ពុជាមានប្រភេទថ្នាំចាត់ស្មៅដែលនិយមប្រើចំនួន  ២

ប្រភេទគឺប្រភេទថ្នាំ ក្លៃហ្វូសេត ឈ្មោះហៅក្រៅនៅខេត្តប៉ៃលិន ទឹកឃ្មុំ និងថ្នាំ អាត្រាសុិនឈ្មោះហៅក្រៅនៅខេត្តប៉ៃលិន អាស្លាន។

សេចក្តីសង្ខេបពីលក្ខណៈរបស់ថ្នាំ

១.៤.១ ថ្នាំ ក្លៃហ្វូសេត ឈ្មោះហៅក្រៅនៅ ខេត្តប៉ៃលិន ទឹកឃ្មុំ




- ប្រភេទនៃការសំលាប់៖ សំលាប់រុក្ខជាតិគ្រប់ប្រភេទដូចជាពពួកស្មៅ ដំណាំពោត សណ្តែក ដំឡូង និងរុក្ខជាតិផ្សេងៗទៀត ដោយមិនរើសទៅលើប្រភេទរុក្ខជាតិ ។
- ពេលវេលាត្រូវប្រើ៖ បាញ់ទៅលើស្មៅ/រុក្ខជាតិចង្រៃមុនពេលភ្ជួរលប់ ឬមុនពេលដាំដំណាំ

រូបភាព ១១ ក្លៃហ្វូសេត ឈ្មោះហៅក្រៅនៅ ខេត្តប៉ៃលិន ទឹកឃ្មុំ

- របៀបនៃការកំចាត់/សំលាប់៖ សំលាប់តាមរយៈជ្រាប មានន័យថានៅពេលថ្នាំប៉ះផ្នែកណាមួយនៃដើមរុក្ខជាតិ វានឹងជ្រាបសប់ដើមរហូតដល់ប្រព័ន្ធឫសហើយធ្វើឱ្យរុក្ខជាតិងាប់ដល់ឫសរយៈពី ៥-១០ ថ្ងៃក្រោយដាំ។មិនត្រូវកាត់ស្មៅ រួចប្រើថ្នាំនេះទេ ដោយសារតែថ្នាំនេះជ្រាបល្អតាមរយៈស្លឹក និងដើម របស់រុក្ខជាតិ ។
- កំរិតជាតិពុល៖ មានកំរិតជាតិពុលទាប ហើយនៅពេលដែលថ្នាំប៉ះនឹងផ្ទៃដី វានឹងលែងមានសកម្មភាព។ ដូច្នេះត្រូវឱ្យប្រាកដថា ទឹកដែលប្រើសំរាប់លាយថ្នាំ ជាទឹកថ្លាល្អ ព្រោះទឹកល្អក់ធ្វើឱ្យបាត់បង់គុណភាពថ្នាំ ។
- ក្រោយពីថ្នាំបានបាញ់លើរុក្ខជាតិរយៈពេល ៤-៦ ម៉ោង វានឹងជ្រាប់សប់ក្នុងដើមរុក្ខជាតិ ប៉ុន្តែបើក្រោយពេលបាញ់រយៈពេលតិចជាង ៤ ម៉ោង មានភ្លៀងវានឹងលាងសំអាតជាតិថ្នាំ និងធ្វើឱ្យគុណភាពថ្នាំ ខ្សោយ ។

១.៤.២ ថ្នាំ អាត្រាសុិន ឈ្មោះហៅក្រៅនៅ ខេត្តប៉ៃលិន អាស្លាន




- ប្រភេទនៃការសំលាប់៖ សំលាប់ទៅលើប្រភេទរុក្ខជាតិ ជាក់លាក់ ដោយជ្រាបដូចជា ពពួកស្មៅ（Grass Weeds） និងរុក្ខជាតិស្លឹកធំ （Broad Leaves）មួយចំនួន។
- ពេលវេលា/របៀបប្រើ៖ ប្រើមុនពេលដាំដំណាំ គឺមុនពេលរុក្ខជាតិឥតប្រយោជន៍ដែលជាពពួកស្មៅ（Grass Weeds） និងរុក្ខជាតិស្លឹកធំ (Broad Leaves) ដុះនិងក្រោយពេលដែលរុក្ខជាតិឥតប្រយោជន៍តូចៗដុះនៅដំណាក់កាលលូតលាស់ដំបូង(Early post emergence)។ ដោយសារថ្នាំ អាត្រាសុិន ត្រូវបាន

រូបភាព ១២ ថ្នាំអាត្រាសុិន ឈ្មោះហៅក្រៅនៅ ខេត្តប៉ៃលិន អាស្លាន

ស្រូបល្អតាមរយៈឫសដំណាំ ដូច្នេះដើម្បីទទួលបានប្រសិទ្ធិភាពខ្ពស់យើងត្រូវបាញ់វាប៉ះនឹងដី តែបើយើងបាញ់ប៉ះ នឹងដើម/ស្លឹក នោះមិនសូវមានប្រសិទ្ធិភាពទេ ។

- កំរិតជាតិពុលៈ កំរិតជាតិពុលមធ្យម និងសល់កាកសំណល់ក្នុងដីរយៈពេលច្រើនខែ ។ នៅសហគមន៍អ៊ឺរ៉ុប ប្រភេទថ្នាំអាច្រាស៊ិនត្រូវបានគេហាមមិនឱ្យប្រើ ដោយសារតែជាតិពុលរបស់ថ្នាំនេះត្រូវបានគេរកឃើញនៅក្នុងដី ទឹកក្រោមដី ទឹកស្ទឹង ជាដើម។

ចំណាំៈ ថ្នាំ អាច្រាស៊ិន ធ្វើឱ្យអន្តរាយខ្លាំងដល់ដំណាំស្រូវ ដូច្នេះ មិនត្រូវលាងជំរះថ្នាំ នៅក្នុងទឹកស្រែទេ ។

## ១.៥. បច្ចេកទេសដាំដុះ

បច្ចេកទេសដាំដុះ គឺយើងធ្វើយ៉ាងណាដើម្បីទទួលបានខ្ពស់ ដោយធ្វើយ៉ាងណាមិនឱ្យចំនួនដើមច្រើនឬដើមតិចពេក ។ តើនៅក្នុងមួយហិកតា គួរមានដើមពោតប៉ុន្មានដែលសមស្រប ដើម្បីទទួលបានទិន្នផលខ្ពស់បំផុត ?

មិនថា ការដាំដោយដៃ ឬដាំដោយប្រើម៉ាស៊ីន គឺត្រូវធ្វើយ៉ាងណាឱ្យចន្លោះគុម្ព និងជួរមានភាពសមស្របបំផុត ។ មានវិធីសាស្ត្រពីរដែលមានលក្ខណៈសមស្រប គឺៈ

- ចន្លោះជួរ (ទ្រូង) ០,៧ ម ឃ ចន្លោះគុម្ភ (កាំ) ០,៥ ម ដាំ ២គ្រាប់ ក្នុង ១ រណ្ដៅ
- ចន្លោះជួរ (ទ្រូង) ០,៧ ម ឃ ចន្លោះគុម្ភ (កាំ) ០,២៥ ម ដាំ ១គ្រាប់ ក្នុង ១ រណ្ដៅ
- ការដាំគ្រាប់គួរមានជំរៅនៅចន្លោះ ២-៥ ស.ម




ចន្លោះជួរ (ទ្រូង) ០,៧ ម x ចន្លោះគុម្ព (កាំ) ០,៥ ម ដាំ ២គ្រាប់ ក្នុង ១ រណ្ដៅ




ចន្លោះជួរ (ទ្រូង) ០,៧ ម x ចន្លោះគុម្ព (កាំ) ០,២៥ ម ដាំ ១គ្រាប់ ក្នុង ១ រណ្ដៅ

## ១.៦. ការប្រើជីទ្រាប់បាត

ការប្រើជីទ្រាប់បាត គឺដើម្បីបង្កើនជីជាតិដីជំរុញការលូតលាស់ និងធ្វើឱ្យដំណាំលូតលាស់នៅពេលចាប់ផ្តើមដំបូង។ ក្នុងករណីដំណាំពោតដុះលូតលាស់ល្អនៅដំណាក់កាលដំបូងគឺបានចូលរួមសំខាន់ក្នុងការធ្វើឱ្យទិន្នផលទទួលបានខ្ពស់ ។ដំណាក់កាលដុះពន្លកដំណាំពោតត្រូវការសារធាតុ ផូស្វ័រ ជាចាំបាច់ដើម្បីធ្វើឱ្យប្រព័ន្ធឫស និងដើមដងមានភាពរឹងមាំហើយកង្វះសារធាតុផូស្វ័រពិបាកនឹងដោះស្រាយណាស់ ដូច្នេះយើងគួរប្រើនៅដំណាក់កាលទ្រាប់បាតជាការប្រសើរ ។ម្យ៉ាងវិញទៀតសារធាតុអាសូតក៏កាន់តែមានសារៈសំខាន់ចំពោះដំណាំពោត ។ ដូច្នេះតើយើងគួរប្រើជីអ្វីដែលប្រសើរនៅដំណាក់កាលទ្រាប់បាត ? គួរប្រើយ៉ាងដូចម្តេច និង នៅពេលណា ?

យើងគួរប្រើប្រភេទជី ដេ អា ប៉េ ដែលជាជំរើសល្អជាងគេនៅដំណាក់កាលទ្រាប់បាត ។ប្រភេទជី ដេ អា ប៉េ មានសារធាតុចិញ្ចឹមសំខាន់ពីរ គឺ អាសូត ១៨% និង ផូស្វរ ៤៦ % ។ ចំពោះការប្រើវិញ ដោយសារធាតុ ផូស្វរនឹងមិនចល័តដូចពពួកជីអ៊ុយរ៉េ ដូច្នេះយើងត្រូវដាក់វាទៅក្នុងដីដែលឫសដំណាំអាចចាក់ដល់ ហើយត្រូវចងចាំគឺមិនត្រូវឱ្យគ្រាប់ពូជដំណាំប៉ះទៅនឹងជីទេព្រោះអាចធ្វើឱ្យរលួយពន្លកដំណាំ ។ យើងអាចប្រើវានៅមុនពេលដាំដំណាំមួយថ្ងៃក៏បានឬនៅថ្ងៃដែលយើងដាំ ។

របៀបនៃការដាក់ជី គឺត្រូវគាប់ទៅក្នុងដី ដោយធ្វើយ៉ាងណាឱ្យវាស្ថិតនៅក្រោម ឬនៅចំហៀងគ្រាប់ពូជ ។




ចំពោះផលប៉ះពាល់ពេលប្រើជី ដេ អា ប៉េ រយៈពេលច្រើនឆ្នាំអាចធ្វើឱ្យដីរបស់យើងឡើងកំរិតជាតិអាស៊ីត ប៉ុន្តែការដែលយើងពុំប្រើជីបន្ថែមក៏ធ្វើឱ្យដីរបស់យើងខូចគុណភាពដែរ ។ ការបន្តប្រើជីធម្មជាតិជាជំរើសល្អក្នុងការថែទាំគុណភាពដី និងបរិស្ថាន ប្រសិនបើអាចរកបាន ។

## វគ្គបណ្តុះបណ្តាលដំណាំពោត ដំណាក់កាល ២ អ្នកនឹងរៀនអំពី:

### ស្មៅ និងវិធានការកំចាត់

### សារធាតុចិញ្ចឹម និងការប្រើជីបំប៉ន

វគ្គបណ្តុះបណ្តាលដំណាក់កាល ២ គឺធ្វើនៅដំណាក់កាលសូតលាស់ ឬពេញផ្កា រីឯទីតាំងនៃវគ្គបណ្តុះបណ្តាលត្រូវធ្វើឡើងនៅចំការដំណាំពោត ដោយតំរូវឱ្យអញ្ជើញកសិករចុះត្រួតពិនិត្យ ផ្ទាល់នៅចំការ ដោយផ្តោតសំខាន់លើ ៥ ចំនុច:

- ស្មៅ និងវិធានការកំចាត់
- សារធាតុចិញ្ចឹម និងការប្រើជីបំប៉ន
- ការត្រួតពិនិត្យមើលកត្តាចង្រៃ និងសត្វល្អិត
- អាចពិភាក្សាអំពីលទ្ធផលនៃការអនុវត្តនៅបណ្តុះបណ្តាលដំណាក់កាល ១

## ២.១. ស្មៅ និង វិធានការកំចាត់

ដូចបញ្ជាក់នៅក្នុងចំនុចទី៤ វគ្គបណ្តុះបណ្តាលដំណាក់កាល១ ដែលថាស្មៅមិនត្រឹមតែបានប្រគួតប្រជែងយកជីជាតិពីដំណាំ គឺបានប្រគួតប្រជែងយកពន្លឺ ខ្យល់ និងទឹកពីដំណាំផងដែរ ។ នៅពេលដែលមានស្មៅដុះច្រើន គឺនឹងធ្វើឱ្យប៉ះពាល់ខ្លាំងដល់ទិន្នផលដំណាំរបស់យើង ។ជាទូទៅវិធីកំចាត់ស្មៅត្រូវបានគេបែងចែកជាពីរប្រភេទគឺវិធីកំចាត់ដោយដៃ និងវិធីប្រើថ្នាំកំចាត់ស្មៅ។ នៅចំនុចនេះ យើងនឹងមិនលំអិតអំពីវិធីកំចាត់ស្មៅដោយដៃទេ ប៉ុន្តែនឹងលំអិតអំពីវិធីកំចាត់ស្មៅដោយប្រើថ្នាំ ។

### ២.១.១ ការប្រើប្រាស់ថ្នាំពុលកសិកម្មកំចាត់ស្មៅ

#### ២.១.១.១ ចំនុចសំខាន់ទូទៅគួរយល់ដឹង

- ការរៀបចំផែនការបាញ់ថ្នាំឱ្យបានច្បាស់លាស់
- ត្រួតពិនិត្យសំភារៈនានាដែលប្រើនៅពេលបាញ់ថ្នាំ ដូចជា ធុងថ្នាំ ទឹក ថ្នាំបាញ់ស្មៅ ជាដើម
- ត្រួតពិនិត្យផ្ទាល់នៅចំការ ដូចជាប្រភេទស្មៅ អាយុកាលលូតលាស់របស់ស្មៅ និងដំណាំ
- ជ្រើសរើសប្រភេទថ្នាំកំចាត់ស្មៅឱ្យត្រូវទៅនឹងប្រភេទស្មៅ
- ត្រូវអានការណែនាំឱ្យបានច្បាស់ដែលមាននៅលើផ្លាកសញ្ញា ជាពិសេសនៅពេលដែលអ្នកលាយប្រភេទថ្នាំច្រើនមុខក្នុងពេលជាមួយគ្នា
- ក្នុងករណីដែលការលូតលាស់របស់ស្មៅត្រូវបានបង្អាក់ ឬខ្សោយ ដូចជា: គ្រោះរាំងស្ងួត ជាំទឹក ខ្វះជីជាតិចិញ្ចឹមនោះការស្រូបយកជាតិថ្នាំដោយស្មៅក៏ត្រូវបានកាត់បន្ថយដែរ ។
- ប្រើទឹកស្អាតសំរាប់លាយថ្នាំ ករណីទឹកភ្លៀងជាការប្រសើរ
- គណនាបរិមាណថ្នាំសំរាប់ប្រើនៅលើផ្ទៃដីឱ្យបានត្រឹមត្រូវ ជៀសវាងការខ្ជះខ្ជាយថវិការ និងបញ្ហានានា
- មិនត្រូវបាញ់ថ្នាំពេលកំពុងភ្លៀងនោះទេ

- ដោយសារថ្នាំបាញ់ស្មៅជាប្រភេទថ្នាំមានជាតិពុល ដូច្នេះត្រូវមានការប្រុងប្រយ័ត្នពេលកំពុងបាញ់ថ្នាំ
- ត្រូវមានសំភារៈការពារខ្លួនខណៈពេលបាញ់ថ្នាំ (ស្បែកជើងករវែង, អាវវែង, ស្រោមដៃ, មាស, មួក...)

### ២.១.១.២. ចំនុចសំខាន់ៗទាក់ទងទៅនឹងថ្នាំបាញ់ស្មៅ

នៅពេលចាប់ផ្តើមប្រើថ្នាំកំចាត់ស្មៅ តើអ្នកត្រូវយល់ដឹងលើចំនុចអ្វីខ្លះអំពីលក្ខណៈរបស់ថ្នាំ?

- ប្រភេទនៃថ្នាំកំចាត់ស្មៅ (តើថ្នាំកំចាត់រុក្ខជាតិប្រភេទអ្វីខ្លះ?)
  - សំលាប់តាមប្រភេទស្មៅជាក់លាក់
  - សំលាប់រាល់រុក្ខជាតិ/ស្មៅគ្រប់ប្រភេទ
- ពេលវេលាត្រូវប្រើ (តើត្រូវប្រើពេលណា ? )
  - មុនពេលដាំ/ មុនពេលដំណាំដុះពន្លក
  - ក្រោយពេលដំណាំដុះពន្លករួច
- របៀបដែលថ្នាំកំចាត់ (តើថ្នាំកំចាត់ស្មៅរបៀបណា ?)
  - សំលាប់ដោយប៉ះ សំលាប់កន្លែងដែលប៉ះនឹងថ្នាំ, មិនជ្រាបទៅកន្លែងផ្សេងទៀតទេ, ដើម្បីមានប្រសិទ្ធភាពត្រូវបាញ់ឱ្យសប់រុក្ខជាតិចង្រៃទាំងមូល ។
  - សំលាប់ដោយជ្រាប នៅពេលថ្នាំប៉ះផ្នែកណាមួយនៃដើមរុក្ខជាតិវានឹងជ្រាបសប់ដើមរហូតដល់ប្រព័ន្ធឫស ហើយធ្វើឱ្យរុក្ខជាតិងាប់ដល់ឫស ។ ថ្នាំប្រភេទខ្លះជ្រាបល្អតាមប្រព័ន្ធឫសដំណាំហើយថ្នាំខ្លះជ្រាបល្អតាមរយៈស្លឹកដំណាំ ។

នៅប្រទេសកម្ពុជា គេឃើញមានប្រភេទថ្នាំកំចាត់ស្មៅចំនួន ៤ ប្រភេទដែលកសិករនិយមប្រើសម្រាប់ដំណាំពោត គឺប្រភេទថ្នាំសំលាប់ស្មៅ ដែលនិយមជួបប្រទះនៅកម្ពុជាសំរាប់ដំណាំពោតមាន ៤ ប្រភេទគឺៈ



រូបភាព ១៣ ប្រភេទថ្នាំ គ្លៃហ្វូសេត ឈ្មោះហៅក្រៅនៅខេត្តប៉ៃលិន ទឹកឃ្មុំ




រូបភាព ១៤ ប្រភេទថ្នាំ ផារ៉ាខ្វត ឈ្មោះហៅក្រៅខេត្តប៉ៃលិន ទឹកឃ្មុំ




រូបភាព ១៥ ប្រភេទថ្នាំអាថ្រាស៊ីនឈ្មោះហៅក្រៅនៅខេត្តប៉ៃលិន អាស្ពាន




រូបភាព ១៦ ប្រភេទថ្នាំ ២,៤ ឌី ឈ្មោះហៅក្រៅនៅខេត្តប៉ៃលិន ឆ្កែអង្គុយ

ថ្នាំកំចាត់ស្មៅក្លែហ្វូសេត, ផារាខ្វត, អាថ្រាស៊ីន និង ២-៤ ឌី ។

ដោយសារប្រភេទថ្នាំក្លែហ្វូសេត និង អាថ្រាស៊ីន បានបញ្ជាក់នៅក្នុងចំនុចទី ៤ នៃ វគ្គបណ្តុះបណ្តាលដំណាក់កាល ១ ដូចនេះ យើងនឹងបញ្ជាក់ តែថ្នាំចំនួន ២ ប្រភេទទៀតទេ គឺថ្នាំកំចាត់ស្មៅ ផារាហ្វត និងថ្នាំ ២-៤ ឌី ។

### ២.១.២ ថ្នាំកំចាត់ស្មៅ ផារាខ្វត ឈ្មោះហៅក្រៅនៅខេត្តប៉ៃលិន ទឹកខ្សៀវ

សេចក្តីសង្ខេប:




- ប្រភេទនៃការសំលាប់: សំលាប់រុក្ខជាតិគ្រប់ប្រភេទដោយប៉ះដូចជា ពពួកស្មៅ ដំណាំពោត សណ្តែក ដំឡូង និង រុក្ខជាតិផ្សេងៗទៀត ដោយមិន រើសប្រភេទរុក្ខជាតិ ។
- ពេលវេលា/របៀបប្រើ: ប្រើក្រោយពេល រុក្ខជាតិឥតប្រយោជន៍ ដុះ លូតលាស់ រួចដោយបាញ់ឱ្យសប់ទៅលើ ដើមរុក្ខជាតិឥត ប្រយោជន៍ ហើយមិន ត្រូវឱ្យទឹកថ្នាំប៉ះនឹងដំណាំទេ ព្រោះនឹងធ្វើឱ្យ ដំណាំងាប់ ឬខូចផ្នែកណាមួយនៃដើមដំណាំ ដែលជាហេតុធ្វើឱ្យមាន ការប៉ះពាល់ដល់ទិន្នផល ។
- កំរិតជាតិពុល: ពុលខ្លាំងប៉ុន្តែនៅពេលដែលថ្នាំប៉ះទៅនឹងដី វាធ្វើឱ្យថ្នាំលែងមានសកម្មភាព ។ ដូច្នេះ ត្រូវឱ្យ ប្រាកដថា ទឹកដែលប្រើសំរាប់លាយថ្នាំ ជាទឹកថ្លាល្អ ព្រោះប្រើទឹកល្អក់ វានឹងធ្វើឱ្យបាត់បង់គុណភាពថ្នាំ ។
- ក្រោយពីថ្នាំបានបាញ់លើរុក្ខជាតិរយៈពេល ៣០ នាទី ភ្លៀងនឹងមិនអាចលាងជំរះជាតិថ្នាំបានទេ ។

### ២.១.៣ ថ្នាំកំចាត់ស្មៅ ២,៤-ឌី ឈ្មោះហៅក្រៅនៅខេត្តប៉ៃលិន ឆ្កែអង្គុយ

សេចក្តីសង្ខេប:

- ប្រភេទនៃការសំលាប់: សំលាប់ដោយជ្រាបលើពពួករុក្ខជាតិស្លឹកធំ
- ពេលវេលា/របៀបប្រើ: ក្រោយពេលរុក្ខជាតិឥតប្រយោជន៍ ស្លឹកធំដុះបានស្លឹក ២ - ៤ ។ ពេលប្រើថ្នាំ ២ - ៤

ឱត្រូវមានការប្រុងប្រយ័ត្ន ព្រោះវាសំលាប់ពពួកដំណាំស្លឹកធំ ដូចជាសណ្តែកបាយ សណ្តែសៀងជាដើម ។ ត្រូវប្រើក្បាលបាញ់មានរុនធំបន្តិចដើម្បីកាត់បន្ថយ ថ្នាំហើរតាមខ្យល់ ។

- កំរិតជាតិពុលៈ ពុលមធ្យម



## ២.១.៤ សុវត្ថិភាពនៃការប្រើប្រាស់ថ្នាំពុល

ហេតុអ្វីត្រូវគិតពីសុវត្ថិភាពពេលប្រើថ្នាំពុល?

តើថ្នាំពុលផ្តល់ផលអាក្រក់អ្វីខ្លះដល់មនុស្ស និងបរិស្ថាន?

### សុខភាពមនុស្ស

ថ្នាំពុលអាចបង្កគ្រោះមហន្តរាយធ្ងន់ធ្ងរដល់សង្គមមនុស្ស និងបរិស្ថាន ។ គេនិយមសង្កេតឃើញ ថ្នាំពុលបានបង្កឱ្យ មនុស្សស្លាប់ និងបង្កជំងឺច្រើន ជាពិសេស នៅបណ្តាលប្រទេសកំពុងអភិវឌ្ឍន៍ ។

### រោគសញ្ញានៃការពុល

| ពុលមធ្យមៈ | ពុលខ្លាំងៈ |
|---|---|
| - ឈឺក្បាល | - កន្ត្រាក់សាច់ដុំ |
| - អស់កំលាំង | - បាត់បង់សតិអារម្មណ៍ |
| - ចង់ក្អួត | - ប្រកាច់ |
| - បែកញើសខ្លាំង | - អាចស្លាប់ |
| - បាត់បង់តុល្យភាព | |
| - ព្រិលផ្នែក | |
| - រម៉ាស់/កន្ទួលលើស្បែក | |



រូបភាព ១៧ ៖ រោគសញ្ញានៃការពុលថ្នាំ

### ថ្នាំពុលជ្រាបចូលតាមរយៈ




រូបភាពនេះ បង្ហាញថាតើថ្នាំពុលអាចជ្រាបចូលក្នុងខ្លួនមនុស្ស តាមកន្លែង ណាខ្លះនៃដងខ្លួនមនុស្សយើង ។ប្រសិនបើមិន មានសំភារៈការពារ ថ្នាំពុលអាចជ្រាបចូលតាមរយៈ ស្បែក ក្បាល ថ្ងាសរុញត្រចៀក ដងខ្លួន ដៃ ឬជើងជាដើម ។

រូបភាព ១៨ ថ្នាំពុល អាចជ្រាបចូលតាមផ្នែកផ្សេងៗនៃដងខ្លួនមនុស្ស

## ការកាត់បន្ថយ ថ្នាំជ្រាបចូលក្នុងខ្លួនយើង



បើទោះបីជា ថ្នាំពុលភាគច្រើន ត្រូវគេសរសេរ ជា ភាសាបរទេសក៏ដោយ ប៉ុន្តែតែមានរូបភាព ដែល បញ្ជាក់អំពីសំភារៈ គួរប្រើខណៈពេលប៉ះពាល់ និង ប្រើប្រាស់ថ្នាំពុល ។ ដើម្បីធានា QuickTime™ and a decompressor are needed to see this picture ។សុវត្ថិភាពពេលប្រើប្រាស់ថ្នាំពុលត្រូវប្រើ សំភារៈសុវត្ថិភាពជានិច្ច ។

រូបភាព ១៩ ថ្នាំពុល សរសេរជាភាសាបរទេសប៉ុន្តែមានរូបសញ្ញាសំភារៈ សុវត្ថិភាព



រូបភាព ២០ ប្រើសំភារៈសុវត្ថិភាព ពេលប្រើថ្នាំពុល

## ផ្នែកបរិស្ថានៈ

ខណៈពេលប្រើថ្នាំពុល តើថ្នាំពុលទាំងនេះនឹងអាចទៅកន្លែងណាខ្លះ?





រូបភាព ២១/២២ របៀបប្រើថ្នាំពុល អាចមានភាពខុសគ្នាទៅតាមតំបន់ និងធនធាន




បន្ទាប់ពីបានប្រើថ្នាំពុលហើយ ថ្នាំពុលទាំងនេះនឹងអាចៈ

- ជ្រាបចូលទៅក្នុងដី
- បំភាយទៅក្នុងបរិយាកាស
- ជ្រាបចូលក្នុងអណ្តូង បឹង...
- ដែលចុងក្រោយ ថ្នាំពុលទាំងនេះ អាចវិលចូលក្នុងខ្លួន មនុស្សយើងវិញតាមមធ្យោបាយផ្សេងៗ

## ២.២ សារធាតុចិញ្ចឹម និងការប្រើជីបំប៉ន

ដីមានកំរិតជីជាតិល្អ ដើរតួនាទីសំខាន់ក្នុងការធ្វើឱ្យទិន្នផលដំណាំទទួលបានខ្ពស់ ។ ពោតជាដំណាំដែលត្រូវការបរិមាណអាសូតក្នុងកំរិតខ្ពស់ ដើម្បីទទួលបានទិន្នផលខ្ពស់ ។ នៅពេលដែលការដាំដុះត្រូវបានធ្វើឡើង ជាច្រើនឆ្នាំ គេសង្កេតឃើញជីជាតិដី ចេះតែធ្លាក់ចុះជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយដើម្បីដោះស្រាយបញ្ហានេះ អ្នកដាំដុះភាគច្រើនបានប្រើជីគីមី ដើម្បីបំពេញបន្ថែមចំពោះបញ្ហាកង្វះខាតនេះ។ ខ្លះមានជំនឿថា នៅពេលប្រើជីគីមីបានធ្វើឱ្យខូចខាតដល់គុណភាពដី ប៉ះពាល់ដល់បរិស្ថាន សុខភាពមនុស្ស និង សត្វ។ អ្នកទាំងនេះ ស្នើរឱ្យមានការប្រើជីធម្មជាតិ ដូចជាលាមកសត្វ កាកសំណល់រុក្ខជាតិ ឬជីកំប៉ុស្តិ៍ដើម្បីទទួលបានទិន្នផលខ្ពស់ កាត់បន្ថយបញ្ហាសត្វល្អិត កាត់បន្ថយជំងឺរុក្ខជាតិ ធ្វើឱ្យប្រសើរឡើងផ្នែកបរិស្ថាន សុខភាពមនុស្ស និងសត្វ ។

អ្នកស្រាវជ្រាវបានបញ្ជាក់ថា ស្ទើរតែគ្រប់ករណីទាំងអស់ នៅពេលដែលឫសរុក្ខជាតិបានចាក់ដល់សារធាតុចិញ្ចឹមទាំងនោះ មិនថាវាមានប្រភពមកពីជីគីមី ឬជីធម្មជាតិទេ គឺការស្រូបយករបស់រុក្ខជាតិនៅក្នុងទំរង់ដូចគ្នា ។ដូច្នេះ ជីគីមី ឬជីធម្មជាតិ នឹងមិនធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់មនុស្សទេ ។

អ្នកស្រាវជ្រាវ ក៏បានបញ្ជាក់អំពីផលចំណេញនៃការប្រើប្រាស់ជីធម្មជាតិដែរថា យើងអាចផលិតជីធម្មជាតិដោយការប្រើកាកសំណល់រុក្ខជាតិ ឬ លាមកសត្វដើម្បីផលិតជាជីសំរាប់ដំណាំស្រូបយកដើម្បីទទួលបានទិន្នផលខ្ពស់ដែរ ។ ប៉ុន្តែដើម្បីទទួលបានសារធាតុចិញ្ចឹមគ្រប់គ្រាន់សំរាប់ដំណាំ គឺទាមទារឱ្យការផលិតបរិមាណជីធម្មជាតិ ក្នុងបរិមាណ

ច្រើនដែរ ហើយនៅពេលដែលយើងប្រើជីធម្មជាតិទាំងនេះដាក់ទៅក្នុងចំការ យើងសង្កេតឃើញ កាកសំណល់ជីធម្មជាតិក៏បានសល់ច្រើនដែរនៅក្នុងចំការ ។កាកសំណល់នេះនឹងធ្វើឱ្យការកើនឡើងពពួកសត្វល្អិត នៅក្នុងដី បាក់តេរី និងពពួកផ្សិតនានា ។អ្វីដែលជាបញ្ហាចំពោះជីធម្មជាតិ គឺពិបាកនៅក្នុងការផលិតឱ្យបានគ្រប់គ្រាន់សំរាប់ប្រើក្នុងផ្ទៃដីចំការធំៗ ។

ការជ្រើសរើសប្រភេទជី និងរបៀបប្រើប្រាស់មិនមែនជាការលំបាកទេ ប៉ុន្តែអ្វីដែលជាបញ្ហានោះ គឺផលចំណេញ/ខាត ខណៈពេលដែលយើងប្រមូលផល និងលក់កសិផលដំណាំរបស់យើង ។ ការគិតអំពីសេដ្ឋកិច្ច មុនពេលចាប់ផ្តើមប្រើប្រាស់ជី មានសារៈសំខាន់ណាស់ ។ចំនុចបន្ទបន្ទាប់ខាងក្រោម នឹងជួយអ្នកធ្វើការសំរេចចិត្តឱ្យបានត្រឹមត្រូវ និងមានទំនុកចិត្តក្នុងការប្រើប្រាស់ជី ។

### ២.២.១ សារធាតុ អាសូត(N)

មានកំរិតសារធាតុអាសូតចំនួន ៣៣000 តោន ក្នុងបរិយាកាសក្នុងទំហំដី ៤០៥០ម$^{២}$ ប៉ុន្តែដំណាំពោតមិនអាចស្រូបយកសារធាតុទាំងនេះពីបរិយាកាសបានទេ គឺអាចស្រូបយកបានតែឧស្ម័នអុកស៊ីសែន អ៊ីដ្រូសែន និងឧស្ម័នកាបូនិចប៉ុណ្ណោះ។ សារធាតុអាសូតបានមកអំពីប្រភពផ្សេងៗនិងទំរង់ខុសគ្នាជាច្រើនផងដែរដូចជា:$NH_3$, $NH_4OH$, $NH_4NH_3$, $(NH_4)sSO_4$, $CO(NH_2)_2$, $NaNO_3$, .. ។ ហើយជាទូទៅដែលដំណាំពោត អាចស្រូបយក អាសូតនៅក្នុងទំរង់ជា $NH_3^{-}$ និង $NH_4^{+}$ ប៉ុន្តែមិនមែនទាំងអស់នោះទេ។ នៅពេលដែលយើងដាក់ជីអាសូតទៅក្នុងដី គឺវានឹងចល័តទៅកន្លែងផ្សេងៗទៀត និងមិននៅមួយកន្លែងដែលអ្នកបានដាក់នោះទេ។ ជីអាសូតនេះដែរគឺងាយនឹងបាត់បង់តាមរយៈ ការហូរច្រោះកំដៅនិងខ្យល់ជាដើម ដូច្នេះហើយទើបការប្រើជីប្រភេទនេះតំរូវឱ្យបែងចែកការប្រើជាច្រើនដំណាក់កាល ។

កង្វះសារធាតុអាសូត នឹងធ្វើឱ្យដំណាំ:

- ដើមតូច: ការលូតលាស់ខ្សោយ ស្គម ស្លឹកមានពណ៌បៃតងស្រលេតស្ទាមឆ្នូតនៅលើស្លឹកហើយស្លឹកនៅផ្នែកខាងក្រោមឆាប់ងាប់ ។
- ផ្លែ: មានទំហំតូច មិនថ្លោសល្អ កំរិតជាតិប្រូតេអ៊ីនធ្លាក់ចុះ និងធ្វើឱ្យទិន្នផលទាប ។



រូបភាព ២៤/២៥ រោគសញ្ញាកង្វះអាសូត (ចុងស្លឹកប្រែពណ៌លឿង និងស្លឹកផ្នែកខាងក្រោមចាប់ផ្តើមងាប់ ។(Source: www.ipni.net )

### ២.២.២ សារធាតុ ផូស្វរ (P)

បរិមាណសារធាតុ ផូស្វរ (P) នៅក្នុងដី និងក្នុងដើមពោត មានចំនួនតិចតួច បើប្រៀបជាមួយនឹងសារធាតុអាសូត និងប៉ូតាស្យូម ប៉ុន្តែទោះជាយ៉ាងនេះក្តី ផូស្វរ មានសារៈសំខាន់ខ្លាំងណាស់សំរាប់ដំណាំពោត។ ផូស្វរនឹងមិនងាយបាត់បង់តាមរយៈ កំដៅ ខ្យល់ ឬហូរច្រោះទេ ហើយសកម្មភាពចល័តនៅក្នុងដីស្ទើរតែគ្មានសកម្មភាព។ ដំណាំពោតស្រូបយកសារធាតុ ផូស្វរ ក្នុងទំរង់ជា $H_2PO_3^-$ និង $HPO_4^-$។ ក្នុងន័យនេះបើទោះបីជាផូស្វរទទួលបានមកពីជីគីមី ឬជីសរីរាង្គក្តីក៏ដំណាំពោតស្រូបយកក្នុងទំរង់ជា $H_2PO_3^-$ និង $HPO_4^-$ ។ ប្រសិនបើខ្វះ ផូស្វរ វានឹងបង្ហាញនៅពេលជាក់លាក់មួយ ដែលជាទូទៅនៅមុនពេលដែលវាមានកំពស់ ០,៧ តឹក ។

កង្វះសារធាតុ ផូស្វរ នឹងធ្វើឱ្យដំណាំ:

- ដើមលូតលាស់មិនល្អ ស្គម និងក្នុងករណីខ្វះខ្លាំង នឹងធ្វើឱ្យដើមក្រិនទាប
- ស្លឹកខ្ចី មានពណ៌បៃតងស្លេក និងស្លឹកចាស់មានពណ៌ស្វាយ
- ពូជខ្លះដើម ស្លឹក មានពណ៌ស្វាយ និងក្រហម
- ទិន្នផលធ្លាក់ចុះយ៉ាងខ្លាំង ព្រោះដើមក្រិនតូច ហើយបើធ្ងន់ធ្ងរ នឹងមិនអាចផលិតផ្លែបានទេ




រូបភាព ២៦,២៧ រោគសញ្ញាខ្វះ ផូស្វរ ដើមក្រិន ផ្នែកខាងដើមនៃដើមមានពណ៌ស្វាយ

កង្វះសារធាតុ ផូស្វរ បណ្តាលមកពី:

- ដីមានសារធាតុសរីរាង្គទាប
- ពេលដាំដំណាំ មិនបានបន្ថែមសារធាតុ ឥផូស្វរ ឱ្យគ្រប់គ្រាន់
- អាកាសធាតុក្តៅខ្លាំង ដីមានជាតិអាស៊ីត សំបូរជាតិដែក

ការកែតំរូវ:

- ជ្រើសរើសប្រភេទជីដែលមានកំរិត ផូស្វរ ខ្ពស់ ដោយដាក់នៅមុន ឬពេលកំពុងដាំ
- យើងអាចប្រើ ជី ដេ អា ប៉េ (DAP) ដែលមាន អាសូត (N) ១៨% និង ផូស្វរ P2O5 ៤៨%
- ផូស្វរ នឹងចល័តខ្សោយណាស់ ដូច្នេះ ត្រូវដាក់ក្បែររណ្តៅពោត ដើម្បីឱ្យឫសដំណាំចាក់ដល់

- ការបន្តប្រើ ដេ អា ប៉េ (DAP) អាចធ្វើឱ្យដីមានកើនជាតិអាស៊ីត
- កាកសំណល់ដំណាំ ដូចជា ដើម ឬស្នូលពោតសំបូរដោយ ផូស្វរ P ដូច្នេះវាជាការប្រសើរណាស់នៅក្នុងការភ្ជួរលប់នូវកាកសំណល់ទាំងនេះ ទៅក្នុងដីវិញ ដើម្បីបង្កើនជីជាតិដី ។

## ២.២.៣ សារធាតុ ប៉ូតាស្យូម (K)

ដំណាំពោតត្រូវការសារធាតុប៉ូតាស្យូម (K) ច្រើន ដើម្បីជំរុញការលូតលាស់ផ្នែកប្រព័ន្ធឫស ដើម ផ្លែ និងធ្វើឱ្យទិន្នផលទទួលបានច្រើន។ សារធាតុប៉ូតាស្យូមមិនងាយនៅក្នុងបាត់បង់ដូចជា អាសូតទេ ។ ជាទូទៅ ប៉ូតាស្យូមមាននៅក្នុងកាកសំណល់ដើមពោតស្នូល និងឫសរបស់របស់ពោត ។ ការដុតកាកសំណល់ដើមពោត ក្រោយពេល ប្រមូលផលនឹងធ្វើឱ្យមានការបាត់បង់ សារធាតុចិញ្ចឹមយ៉ាងច្រើនជាពិសេស ប៉ូតាស្យូមនិង ផូស្វរ។ ដំណាំពោតស្រូបយកប៉ូតាស្យូមក្នុងទំរង់ជា ($K^+$)

កង្វះសារធាតុប៉ូតាស្យូមអាចបណ្តាលឱ្យ:

- ធ្វើឱ្យការលូតលាស់របស់ដំណាំពោតខ្សោយ ដើមទាប ស្គម
- ស្លឹកខ្ចីមានពណ៌ប៉ៃតងស្លេក និងស្លឹកចាស់ឆាប់ងាប់
- ទិន្នផលធ្លាក់ចុះយ៉ាងខ្លាំង នៅពេលដែលដំណាំពោតខ្វះ ប៉ូតាស្យូម



រូបភាព ២៨ រោគសញ្ញាខ្វះ ប៉ូតាស្យូម ដើមក្រិន ផ្នែកខាងដើមនៃស្លឹកប្រែពណ៌លឿង

ការកែតំរូវៈ

- ជ្រើសរើសប្រភេទជីដែលមានកំរិតប៉ូតាស្យូមខ្ពស់ ដោយដាក់នៅមុន ឬពេលកំពុងដាំ
- ប៉ូតាស្យូមមានជាតិប្រៃដែលអាចធ្វើឱ្យរលួយពន្លកពោត ដូចនេះ ត្រូវដាក់ជី នៅឆ្ងាយពីគ្រាប់ពូជបន្តិច
- គួរបន្ថែមជីប៉ូតាស្យូមក្លរ (KCl) ផ្សំឡើងអំពីអំបិលប៉ូតាស្យូម និងក្លរ (Cl) ដែលមានពណ៌ស លាយក្រហម ។
- ការភ្ជួរលប់កាកសំណល់ដំណាំពោត មានចាំបាច់ដើម្បីបង្កើនជីសរីរាង្គ ជាពិសេស ធាតុប៉ូតាស្យូម

### ២.២.៤ របៀបនៃការប្រើជីបំប៉ន



- ត្រូវសំអាតស្មៅឱ្យបានស្អាត មុនពេលប្រើជី
- រោយជីនៅក្បែរគល់ដំណាំ ហើយត្រូវលុបដី
- អាចកាយ ជារណ្ដៅតូចៗ រួចដាក់ជីក្នុងរណ្ដៅបន្ទាប់មកត្រូវលុបដី
- កាន់តែប្រសើរ ក្នុងករណីយើងអាចពូនគល់ដំណាំ

រូបភាព ២៩ របៀបនៃការដាក់ជី ដោយរោយនៅតាមគល់ដំណាំ ហើយពូនគល់ដំណាំ

កសិករភាគច្រើន បានលើកជាសំណួរ ថា *តើយើងអាចលាយជីនៅទឹក រួចប្រើធុងបាញ់ទៅលើដំណាំពោតបានដែរ រឺទេ?* ហាក់បីដូចជាខុសគ្នាបន្តិចចំពោះដំណាំពោតជាមួយដំណាំបន្លែដូចជាៈ ត្រកួន, ស្ពៃជាដើម ដែលកសិករនិយមប្រើជីលាយនៅក្នុងទឹក រួចស្រោចលើដំណាំបន្លែរបស់គាត់ ព្រោះដំណាំពោត មានអាយុកាលវែងខ្លាំង បើប្រៀបធៀបទៅនឹងបន្លែ ។ បើទោះបីជា ដំណាំពោតអាចស្រូបយកសារធាតុចិញ្ចឹមទឹក និងខ្យល់តាមរយៈស្លឹកក៏ដោយ ប៉ុន្តែអត្រានៃការបាត់បង់សារធាតុចិញ្ចឹមមានកំរិតខ្ពស់បើប្រៀបធៀបទៅនឹងការគាប់ជីទៅក្នុងដី ។ជាទូទៅឫសដំណាំពោតបានដើរតួរយ៉ាងសំខាន់នៅក្នុងការស្រូបយកសារធាតុចិញ្ចឹមពីក្នុងដីសំរាប់ការលូតលាស់ប៉ុន្តែស្លឹកពោតមិនអាចបំលែងជីបរិយាកាស ឧទាហរណ៍ អាសូត សំរាប់ចិញ្ចឹមដើមរបស់វាបានទេ ។ ខណៈពេលស្រោចទឹកជី ដំណាំឆាប់ប្រែ ពណ៌ខៀវ ហើយក៏ឆាប់អន់ទៅវិញដែរ ។ ក្នុងករណី កំហាប់ជីខ្ពស់ នោះអាចធ្វើឱ្យស្លឹកដំណាំពោតខ្លោច ខូចផងដែរ ។ ដូច្នេះ វាជាការប្រសើរក្នុងករណីជី ត្រូវបានកាប់ទៅក្នុងដី ហើយដំណាំមានភាពងាយស្រួលក្នុងការស្រូបយក ។

## វគ្គបណ្តុះបណ្តាលដំណាំពោត ដំណាក់កាល ៣ អ្នកនឹងរៀនអំពីៈ

### ការប្រមូលផល

### ការហាលសម្ងួត និងការរក្សាទុក

វិធីសាស្ត្រនៅដំណាក់កាលទី ៣ បានបញ្ចូលវគ្គបណ្តុះបណ្តាល ជាមួយនឹងការធ្វើទិវាបង្ហាញអំពីលទ្ធផលដល់អ្នកចូលរួមទាំងអស់ដោយផ្តោតសំខាន់លើ ៥ ចំនុចៈ

- ការប្រមូលផល
- ការហាលសំងួត និងស្តុកទុក
- ការវាស់ស្ទង់ទិន្នផល និងការវិភាគសេដ្ឋកិច្ច
- សង្ខេបបច្ចេកទេសនៅវគ្គបណ្តុះបណ្តាលដំណាក់កាល ១ និង ដំណាក់កាល ២
- ព័ត៌មានត្រឡប់អំពីអ្នកចូលរួម

## ៣.១. ការប្រមូលផល

ពោតទុំ នៅពេលដែលវាមានសំណើមចាប់ពី ៣០ ទៅ ៣២% ប៉ុន្តែត្រូវរងចាំរហូតដល់សំណើមនៅចន្លោះ ១៨ % ទៅ ២៤ %។ ចំពោះកសិករអាចមានការលំបាក ក្នុងការកំណត់ភាពទុំរបស់ពោតតាមរយៈ ការគិតអំពីសំណើមគ្រាប់ ដោយសារតែស្ទើរតែកសិករទាំងអស់ មិនមានឧបករណ៍សម្រាប់វាស់សំណើមគ្រាប់ទេ ដូច្នេះត្រូវដឹងអំពីលក្ខណៈត្រូវប្រមូលផល ដូចខាងក្រោម៖

- ពេលទុំ ពណ៌ស្លឹក ដើម និងសំបកផ្លែ គឺអាស្រ័យទៅលើពូជ និងរដូវកាល ។ នៅដើមរដូវ (ខែមិនា-កក្កដា) ដើមពោត និងស្លឹកផ្នែកខាងលើ នៅមានពណ៌បៃតង តែស្លឹកខាងក្រោម និងសំបកផ្លែ មានពណ៌លឿងស្ងួត ហើយ នៅរដូវចុងដៃ (ខែកក្កដា-ខែធ្នូ)ទាំងដើម ស្លឹក និងសំបកផ្លែ ងាប់ទាំងអស់ ដែលមានពណ៌លឿងស្ងួតដូចចំបើង
- គ្រាប់ពោតស្ងួត រឹង រលោង ភ្លឺ និងឡើងជាតិម្សៅច្រើន
- ពូជខ្លះនៅពេលទុំ ផ្លែសំយ៉ុងចុះក្រោម
- ត្រូវប្រមូលផលឱ្យគ្រប់អាយុពោត ដែលបានបញ្ជាក់ដោយក្រុមហ៊ុនផ្គត់ផ្គង់ពូជ ដើម្បីជៀសវាង៖
  - ពោតទុំជ្រុល នៅពេលកិនគ្រាប់ ធ្វើឱ្យអត្រាប្រេះ ស្រាំគ្រាប់មានកំរិតខ្ពស់
  - ពេលភ្លៀង អាចធ្វើឱ្យគ្រាប់អាប់ពណ៌ ដុះផ្សិត ឬប្រេះ ចំពោះពូជមានសំបកផ្លែ គ្របមិនជិតស្អិត



រូបភាព ៣០ ស្ថានភាព ពោតទុំនៅរដូវដើមដៃ ។ កសិករនៅ ប៉ៃលិន និយមប្រមូលផលនៅពេលគ្រាប់មានសំណើម ២៩%



រូបភាព ៣១ ស្ថានភាព ពោតទុំនៅរដូវចុងដៃ ។ កសិករនៅ ប៉ៃលិន និយមប្រមូលផលនៅពេលគ្រាប់មានសំណើម ២១%

## ៣.២ ការហាលសំងួត និងស្តុកទុក

ចាំបាច់ត្រូវរួសរ៉ាន់ហាលសំងួតពោតបន្ទាប់ពីធ្វើការបកសំបកឬកិនគ្រាប់រួច ។ ការស្តុកទុកក្នុងរយៈពេលយូរគឺទាមទារ ឱ្យមានការហាលសំងួតរហូតដល់សំណើមគ្រាប់ធ្លាក់ដល់ ១៣% ។ កាលណាយើងស្តុកទុកពោតដោយមានសំណើមខ្ពស់នឹងអាចធ្វើគ្រាប់ពោតដុះផ្សិត ឡើងផ្អូរ អាប់ពណ៌ និងអាចដុះពន្លកក្នុងករណីពោតមានសំណើមខ្ពស់។ ចំពោះការស្តុកទុកទាំងស្នួលគួររក្សាក្នុងជង្រុកដែលមាន ខ្យល់បក់កាត់តាមជញ្ជាំងបានគ្រប់គ្រាន់ ហើយត្រូវហាលពោតឱ្យស្ងួតល្អ ដើម្បីជៀសវាងការចេះសំណើមពីស្នួលនិងធ្វើឱ្យពោតដុះពន្លក ។ ចំពោះពូជខ្លះ មិនអាចស្តុកទុកទាំងស្នួលបានរយៈពេលយូរទេ ព្រោះស្នួលងាយនឹងពុកផុយ ដែលពិបាកនៅពេលកិនគ្រាប់ក្នុងករណីរក្សាទុកទាំងស្នួល ។



ស្ថានភាពការទុកដាក់ពោត ក្រោយពេលប្រមូលផលរបស់កសិករភាគច្រើននៅប៉ៃលិនៈ
ជាទូទៅកសិករនៅប៉ៃលិន ប្រើការុងច្រកពោតរួចរៀបធ្វើ ជាជញ្ជាំងសំរាប់ដាក់ពោត ដែលបានប្រមូលផលរួចនៅចំការ ។ ចំពោះការប្រមូលផលវិញ គឺធ្វើឡើងដោយដៃរួច ច្រកការុងដើម្បីគិតការចំណាយក្នុងពេលប្រមូលផល ។

រូបភាព ៣២ បច្ចេកទេសដែលកសិករនៅប៉ៃលិន ស្តុកពោតក្រោយពេលប្រមូលផល ហើយរងចាំ កិនគ្រាប់ ប លក់

តើការអនុវត្តន៍តាមវិធីមានផលប៉ះពាល់យ៉ាងណា ?

ជាទូទៅ ពោតមានសំណើមខ្ពស់ ក្រោយពេលប្រមូលផល ហើយនៅពេលដែលយើងក្រចពោតក្នុងការុង បន្ទាប់ពីប្រមូលផលរួចវានឹងធ្វើឱ្យពោតហប់ឡើងកំដៅដែលងាយនឹងធ្វើឱ្យអាប់ពណ៌ មានក្លិនស្អុយ ឡើងផ្សិតនិងជំងឺផ្សេងៗ ។ វានឹងត្រូវគេទំលាក់តំលៃ ក្នុងករណីពោត ទិញដោយគិតទៅលើគុណភាព។

បន្ទាប់ពីការកិនគ្រាប់ពោតរួចហើយក្រចក្នុងការុងយើងត្រូវប្រាកដថាគ្រាប់ពោតមានសំណើមទាប។ ក្នុងករណីស្តុករយៈពេលយូរ ដើម្បីធានាបាននូវគុណភាព សំណើមគ្រាប់ត្រូវស្មើឬ ទាបជាង ១៣ % ។ យើងនឹងមិនអាច វាស់សំណើម គ្រាប់បានទេ ប្រសិនបើ អ្នកគ្មានឧបករណ៍វាស់សំណើមគ្រាប់

ប៉ុន្តែនៅពេលដែលអ្នកបានវាស់សំណើមគ្រាប់ដោយប្រើឧបករណ៍នោះ អ្នកនឹងអាចប៉ាន់ស្មានបានអំពីកំរិតសំណើម ។



រូបភាព ៣៣ គ្រាប់ពោតច្រកក្នុងការុង ក្រោយពេលកិនគ្រាប់ រួច រងចាំការលក់

ខាងក្រោមនេះ  គឺជាឧបករណ៍ដែលគេប្រើសំរាប់វាស់សំណើមគ្រាប់របស់ពោតនិងអាចប្រភេទដំណាំមួយចំនួនទៀត ដូចជា: ស្រូវ សណ្តែកសៀង សណ្តែកបាយជាដើម ។












រូបភាព ៣៤/៣៥/៣៦/៣៧  ឧបករណ៍ត្រូវបានគេប្រើសំរាប់វាស់សំណើម គ្រាប់

## ឯកសារយោង:


Aldrich, damma R. and Leng, Earl R. (1966), ‘Hybrid Selection’, Section 3 in Modern Corn Production, F+W Publishing Crop., Cincinati, Ohio, pp.29-36

Belfield, S. and Brown C. (2008), ‘Nutrition’, in Field Crop Manual: Maize, NSW Department of Primary Industries, Australia. pp.18

IPNI Web page: http//: www.ipni.net /Nitrogen accessed 22 October 2009

Manning, W., Fleming, J., Storrie, A. and Cook, T. (2008-09), Weed Control in Summer Crops, NSW Department of Primary Industries, Australia.

Tisdale, Samuel L., Nelson, Werner L., Beaton James D. and Havlin John L. (2002) ‘ Soil and Fertilizer: Nitrogen, Phosphorus and Potassium’, Chapter 5, 6, 7 in Soil Fertility and Fertilizers, New Delhi.